| កិច្ចតែងការ | |
| --- | --- |
| **មុខវិជ្ជា** | ភាសារខ្មែរ (សិក្សាសង្គម) |
| **ប្រធានបទ** | ភាសារខ្មែរៈ<br>-កាស្តាប់<br>(សិក្សាសង្គមៈ<br>-គំនូរ និងសកម្មភាពកសាង<br>បុរេគណិតៈស្គាល់ចំនួន និងព៌ណ) |
| **ចំណងជើងមេរៀន** | ល្បែងស្តាប់ពណ៌ (ដកស្រង់ពីរឿង"  តើនរណាជាអ្នកលាបពណ៌មេឃ?") |
| **កម្រិត** | ទាប  ៣០ នាទី |
| **គោលបំណង** | ភាសារខ្មែរៈ<br>-ស្តាប់គេនិយាយ និងមានសមត្ថភាពស្តាប់ដោយធ្វើតាមការណែនាំងាយៗ។<br>(សិក្សាសង្គមៈ<br>-ដើម្បីឱ្យកុមារប្រាប់បានពីរបៀបគូរ និងផាត់ពណ៌រូបភាព។) |
| **បំណិនសម្បទា** | ភាសារខ្មែរៈ<br>-បង្ហាញពីសកម្មភាពតាមការនែនាំទៅតាមដំណាក់កាលនីមួយ។<br>(សិក្សាសង្គមៈ<br>-គូរ និងផាត់ពណ៌រូបគំនូរ។) |
| **ចរិយាសម្បទា** | ភាសារខ្មែរៈ<br>-ព្យាយាម អំណត់ និយកចិត្តទុកដាក់ក្នុងការស្តាប់។ |

| | |
|---|---|
| | (សិក្សាសង្គមៈ<br>-អមណត់ ព្យាយាម សហការ យកចិត្តទុកដាក់គួរ និងផាត់ពណ៌ ហើយចេះទទួលស្គាល់ស្នាដៃរបស់ខ្លួន និងអ្នកដ៏ទៃ។) |
| **គ្រូបង្រៀន** | ធ្វើក្រដាស់ពណ៌ខុសៗគ្នានៃឥន្ទធនូ ដូច្នេះអ្នកអាចជួយក្មេងៗប្រសិនបើចាំបាច់។<br>បោះពុម្ពសន្លឹកកិច្ចការចេញ (សន្លឹកមួយសម្រាប់ក្មេងម្នាក់ៗ)។ |
| **កុមារ** | តាមស្ថានភាពជាក់ស្តែងនៅពេលលេង។ |
| **រៀបចំ** | សន្លឹកកិច្ចការ (B3-PW-12a_ល្បែងផាត់ពណ៌ឥន្ទធនូ_៧ពណ៌, B3-PW-12b_ល្បែងផាត់ពណ៌ឥន្ទធនូ_៥ពណ៌) និងខ្មៅដៃពណ៌ ។ |

| **សកម្មភាពគ្រូបង្រៀន** | **មាតិកា** | **សកម្មភាពសិស្ស** |
|---|---|---|
| 1. ចូរឱ្យក្មេងៗប្រាប់ពីឈ្មោះពណ៌ទាំង៧ របស់ឥន្ទធនូ។<br>2. នៅពេលដែលក្មេងម្នាក់បានឆ្លើយ ចូរសួរក្មេងម្នាក់ផ្សេងទៀតឱ្យប្រាប់ពីវត្ថុដែលមានពណ៌ដូចនឹងពណ៌ដែលក្មេងម្នាក់នោះបានឆ្លើយ។<br>3. បន្តធ្វើសកម្មភាពបែបនេះរហូតដល់គ្រប់៧ ពណ៌។ | 1. ក្មេងដំបូងចាប់ផ្តើមជាមួយនឹងពណ៌ក្រហម និងនិយាយថា ‹‹នៅក្នុងកន្ត្រករបស់ខ្ញុំមាន (ដាក់វត្ថុដែលមានពណ៌ក្រហម)...» ឧ. ផ្លែប៉េងប៉ោះ។<br>2. ក្មេងទី២និយាយតទៀតថា ‹‹នៅក្នុងកន្ត្រករបស់ខ្ញុំមានប៉េងប៉ោះ ហើយ (ដាក់វត្ថុដែលមានពណ៌ក្រហមមួយមុខទៀត) ··· ›› ឧ. មាន ប៉េងប៉ោះ ប៉ោម។ | 1. ស្តាប់គ្រូរបស់អ្នកនិងឆ្លើយសំណួររបស់គាត់ដែលបានសួរ។<br>2. ព្យាយាមស្តាប់ឱ្យយល់ពីច្បាប់នៃការលេងល្បែងមួយនេះ។<br>3. ព្យាយាមនឹកឃើញវត្ថុដែលមានពណ៌ផ្សេងៗពីគ្នាដែល |

| | | |
|---|---|---|
| 4. ធ្វើការណែនាំល្បែងនេះ និងពន្យល់ពីច្បាប់នៃការលេង។<br>5. ចូរឱ្យក្មេងម្នាក់ទៀតចាប់ផ្ដើម។<br>6. ប្រសិនបើមានបញ្ហា ឬមិនយល់ អ្នកអាចនិយាយឧទាហរណ៍ខ្លះជាការរំលឹកឱ្យពួកគេដឹងនឹងឱ្យពួកគេនឹកឃើញពាក្យដែលត្រូវនិយាយ។<br>7. នៅពេលដែលក្មេងមានអារម្មណ៍ថាធុញថប់ ឬប្រសិនបើអ្នកអស់ពេលក្នុងការលេងល្បែងនេះ អ្នកអាចចែកសន្លឹកកិច្ចការទៅពួកគេបាន។<br>8. នៅពេលដែលក្មេងៗទាំងអស់ទទួលបានខ្មៅដៃពណ៌ និងឱ្យពួកគេផាត់ពណ៌ទៅតាមពណ៌ដែលមាននៅខាងក្រោមរូបនីមួយៗជាការស្រេច។ | 3. ក្មេងទី៣និយាយឈ្មោះផ្លែទាំង២និងដាក់វត្ថុ ឬផ្លែមួយទៀត ដែលមានពណ៌ក្រហមដូចគ្នា។<br>ឧ. ‹‹នៅក្នុងកន្ត្រករបស់ខ្ញុំមានផ្លែប៉េងប៉ោះផ្លែប៉ោម និងផ្លែស្រកានាគ…››<br>4. ធ្វើបែបនេះរហូតដល់មានក្មេងណាម្នាក់ភ្លេចវត្ថុ ឬពណ៌ដែលពួកគេបាននិយាយទាំងនោះ និងមិនអាចនិយាយវត្ថុ ឬផ្លែឈើអ្វីផ្សេងទៀតបាន ហើយពួកគេទាំងនោះ នឹងត្រូវចាកចេញពីការលេងល្បែងនោះ។<br>5. បន្ទាប់មកទៀត ចាប់ផ្ដើមលេងជាមួយនឹងពណ៌មួយផ្សេងទៀតរបស់ពណ៌ឥន្ទធនូដែលមានពណ៌ទឹកក្រូច ។<br>6. បន្តធ្វើ ឬលេងបែបនេះរហូតដល់គ្រប់ពណ៌ទាំង៧របស់ឥន្ទធនូ។ ដូចជាពណ៌៖ ស្វាយ ខៀវស្វាយ និងពណ៌ផ្សេងទៀតដែលមានក្នុងពណ៌របស់ | បានប្រាប់នៅក្នុងការលេងល្បែង។<br>4. ចូរចងចាំពាក្យឱ្យបានច្បាស់ និងត្រូវទៅតាមលេខរៀង នៅពេល ដល់វេនរបស់អ្នក។<br>5. ប្រសិនបើអ្នកភ្លេចពាក្យដែលពួកគេបាន និយាយតាមលេខរៀងនោះ អ្នកនឹងចាញ់។ |

| | | |
|---|---|---|
| | ឥន្ធធនូ។<br>7.ល្បែងនេះអាចលេចជាក្រុមក៏បានដែរ។ | |